ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០៣៥ ភកា៩

# សេចក្តីណែនាំ

## ស្តីពី

## នីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល បំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ

ដោយអនុវត្តតាមអនុក្រឹត្យលេខ៩៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃសម្រេចដាក់ចេញនូវនីតិវិធីស្តីពីការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលបំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅតាមបណ្តាក្រុង ស្រុក ខណ្ឌគោលដៅទាំងអស់ សម្រាប់អនុវត្តដូចខាងក្រោម៖

### ក. ចំពោះប្រធាន អនុប្រធានការិយាល័យ មន្ត្រីជួរមុខ និងមន្ត្រីជំនួយការប្រធានការិយាល័យប្រជាពលរដ្ឋ

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលត្រូវបំពេញការងារក្នុងមុខតំណែងជាប្រធាន អនុប្រធានការិយាល័យច្រកចេញចូលតែមួយ មន្ត្រីជួរមុខ (មន្ត្រីទទួល ប្រគល់ឯកសារ និងផ្តល់ព័ត៌មាន មន្ត្រីនីត្យានុកូលកម្ម និងមន្ត្រីបេឡាករ) និងមន្ត្រីជំនួយការប្រធានការិយាល័យប្រជាពលរដ្ឋ ត្រូវធ្វើឡើងដោយដីការបស់អភិបាលរាជធានី ខេត្តសាមី តាមសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌសាមី បន្ទាប់ពីមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។

ចំពោះបេក្ខជនដែលស្នើតែងតាំង ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដូចបានកំណត់ដោយលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងតារាងឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីណែនាំនេះ។ ក្នុងករណីដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំមានមន្ត្រីដែលមានលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យសមស្របសម្រាប់ការស្នើសុំតែងតាំងក្នុងមុខតំណែងទាំងនេះទេនោះ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន អាចស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្តសាមី ដើម្បីជ្រើសរើសបេក្ខជនដែលមាន

លក្ខណសម្បត្តិសមស្របពីសាលារាជធានី ខេត្ត ឬពីសាលាក្រុង ស្រុក ខណ្ឌផ្សេងទៀត ឬស្នើសុំផ្ទេរមន្ត្រីពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតបាន តាមនីតិវិធីជាធរមាន។

ផ្អែកតាមសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវពិនិត្យអំពីលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យរបស់មន្ត្រីដែលត្រូវបានស្នើតែងតាំងដោយផ្អែកតាមការកំណត់នៃលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងតារាងឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីណែនាំនេះ។ ករណីបេក្ខជនដែលស្នើសុំតែងតាំងនោះពុំសមស្របនឹងលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យដែលបានកំណត់ អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបមកអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីជ្រើសរើសបេក្ខជនថ្មីដែលមានលក្ខណវិនិច្ឆ័យ និងឧបនិស្ស័យសមស្របមកជំនួស។ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាល និងស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន មុននឹងលើកសំណើបេក្ខជនថ្មីនេះជូនអភិបាលរាជធានី ខេត្ត។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចបានកំណត់ខាងលើនេះ អភិបាលក្រុង ស្រុក ខណ្ឌសាមីត្រូវធ្វើការប្រជុំពិភាក្សាឲ្យមានការឯកភាពគ្នាក្នុងគណៈអភិបាល និងសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួនអំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមីពិនិត្យ សម្រេច។

**ខ. ចំពោះមន្ត្រីជួរក្រោយ**

ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលបំពេញការងារនៅផ្នែកជួរក្រោយ (មន្ត្រីជំនាញរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព) ត្រូវធ្វើឡើងដោយដីការបស់អភិបាលរាជធានី ខេត្តសាមីតាមសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌសាមី តាមរយៈប្រធានមន្ទីរ អង្គភាពសាមី បន្ទាប់ពីមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌរបស់ខ្លួន។

ផ្អែកលើសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ និងមតិយោបល់របស់ប្រធានមន្ទីរ អង្គភាពសាមី អភិបាលរាជធានី ខេត្ត ត្រូវយកសំណើនេះមកពិនិត្យ និងពិភាក្សាឲ្យមានការឯកភាពគ្នានៅក្នុងគណៈអភិបាលរបស់ខ្លួន មុននឹងចេញដីកាតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីក្នុងមុខតំណែងទាំងនេះតាមនីតិវិធីជាធរមាន។

ចំពោះបេក្ខជនដែលស្នើតែងតាំងនេះ ត្រូវជ្រើសចេញពីមន្ត្រីរាជការស៊ីវិលដែលមានបទពិសោធន៍ និងជំនាញបច្ចេកទេសក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័នសាមីនីមួយៗ ដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងសេចក្តីណែនាំនេះ។ ក្នុងករណីដែលពុំអាចជ្រើសរើសបាននូវបេក្ខជនសមស្របនោះទេ អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ត្រូវស្នើសុំយោបល់ពីអភិបាលរាជធានី ខេត្ត ដើម្បីសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីក្នុងការស្នើសុំផ្ទេរមន្ត្រីមកពីក្រសួង ស្ថាប័ន ឬពីមន្ទីរ អង្គភាពជំនាញនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្សេង ឬពីក្របខ័ណ្ឌក្រសួង ស្ថាប័នផ្សេងទៀតតាមនីតិវិធីជាធរមាន។

ក្នុងករណីតម្រូវឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងខាងលើនេះ អភិបាលក្រុង ស្រុក ខណ្ឌសាមីដោយមានការឯកភាពពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនត្រូវបញ្ជាក់អំពីមូលហេតុជាក់លាក់នៃការស្នើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចនេះ ដើម្បីលើកសំណើជូនអភិបាលរាជធានី ខេត្តសាមីពិនិត្យ សម្រេច តាមរយៈប្រធានមន្ទីរ អង្គភាពសាមី។

ក្នុងករណីចាំបាច់ អភិបាលរាជធានី ខេត្ត អាចចាត់ឲ្យមានការស៊ើបអង្កេតជាមុនចំពោះមូលហេតុដែលស្នើសុំឲ្យមានការផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងដូចមានកំណត់ក្នុងចំនុច ក និងចំនុច ខ ខាងលើនេះ។ ក្នុងករណីការស៊ើបអង្កេតរកឃើញថា សំណើនេះពុំមានមូលហេតុសមស្រប អភិបាលរាជធានី ខេត្ត ត្រូវធ្វើលិខិតជម្រាបមកអភិបាលក្រុង ស្រុក ខណ្ឌ អំពីការមិនគាំទ្រចំពោះសំណើសុំផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនេះ។ ក្នុងករណីការស្នើសុំនេះមានមូលហេតុជាក់លាក់ អភិបាលរាជធានី ខេត្ត ត្រូវចេញដីកាផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីនោះតាមការស្នើសុំ។

អភិបាលរាជធានី ខេត្ត ត្រូវបញ្ជូនដីកាតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលតាមសេចក្តីណែនាំនេះមកក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីរបស់មន្ត្រីដែលបានតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃតែងតាំង ឬផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ច ដើម្បីពិនិត្យនីត្យានុកូលភាព និងបំពេញបែបបទពាក់ព័ន្ធនឹងប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ ការងារក្របខ័ណ្ឌ និងការធានាការអនុវត្តតាមនីតិវិធីជាធរមាន។

ដើម្បីធានាឲ្យការគ្រប់គ្រង ការចាត់ចែង និងការសម្របសម្រួលការបំពេញការងារនៃការិយាល័យច្រកចេញចូលតែមួយប្រកបដោយប្រសិទ្ធភាព អភិបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗ ត្រូវប្រគល់ភារកិច្ចជូនអភិបាលរងក្រុង ស្រុក ខណ្ឌមួយរូបទទួលបន្ទុកលើកិច្ចការនេះ។

គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ[illegible] ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**កន្លែងទទួល ÷**

- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត*
  *"ដើម្បីជ្រាបជាព័ត៌មាន"*
- *រដ្ឋបាលថ្នាក់ក្រោមជាតិ*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*

## តារាងឧបសម្ព័ន្ធភ្ជាប់សេចក្តីណែនាំលេខ០៣៥. ចុះថ្ងៃទី.២១.ខែ.វិច្ឆិកា..ឆ្នាំ២០១៣
## ស្តីពីការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិល
## បំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ

### លក្ខណសម្បត្តិ និងលក្ខណវិនិច្ឆ័យសម្រាប់ជ្រើសរើសមន្ត្រីតែងតាំងបំពេញការងារ
### នៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ

| ល.រ | មុខតំណែង | ក្របខ័ណ្ឌ ឋានន្តរសក្តិ (អប្បបរមា) | កំរិតវប្បធម៌ | ជំនាញ | បទពិសោធន៍ការងារ |
|---|---|---|---|---|---|
| ១ | ប្រធានការិយាល័យច្រកចេញចូលតែមួយ | ក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរសក្តិ ក្រមការ | សញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្ររងឡើងទៅ | - គ្រប់គ្រងរដ្ឋបាល<br>- សម្របសម្រួល<br>- កុំព្យូទ័រ | ធ្លាប់គ្រប់គ្រងការងាររដ្ឋបាលនៅក្នុងអង្គភាពរដ្ឋ ឬឯកជនរយៈពេលពីរឆ្នាំឡើង |
| ២ | អនុប្រធានការិយាល័យច្រកចេញចូលតែមួយ | ក្របខ័ណ្ឌលេខាធិការរដ្ឋបាល គ្រប់ឋានន្តរសក្តិ | សញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្ររងឡើងទៅ | - គ្រប់គ្រងរដ្ឋបាល<br>- សម្របសម្រួល<br>- កុំព្យូទ័រ | ធ្លាប់គ្រប់គ្រងការងាររដ្ឋបាលនៅក្នុងអង្គភាពរដ្ឋ ឬ ឯកជនរយៈពេលមួយឆ្នាំឡើង |
| ៣ | មន្ត្រីជួរមុខទទួលបន្ទុកផ្នែកបេឡា | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | - គណនេយ្យ បេឡា<br>- កុំព្យូទ័រ | ធ្លាប់ធ្វើការងារផ្នែកគណនេយ្យ និងបេឡាករ |
| ៤ | មន្ត្រីជួរមុខទទួលបន្ទុកទទួលប្រគល់ឯកសារ និងផ្តល់ព័ត៌មាន | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | - គ្រប់គ្រងឯកសារ<br>- ការងាររដ្ឋបាល<br>- ការងារទំនាក់ទំនង<br>- កុំព្យូទ័រ | - ធ្លាប់ធ្វើការងាររដ្ឋបាល<br>- ធ្លាប់ធ្វើការងារទំនាក់ទំនងសាធារណៈ |

| | | | | | |
|---|---|---|---|---|---|
| ៥ | មន្ត្រីផ្នែកជួរមុខទទួលបន្ទុកការងារនីត្យានុកូលកម្ម | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | - ការងាររដ្ឋបាលនិងច្បាប់<br>- ការងារទំនាក់ទំនង<br>- កុំព្យូទ័រ | ធ្លាប់ធ្វើការងាររដ្ឋបាល |
| ៦ | មន្ត្រីជំនួយការប្រធានការិយាល័យប្រជាពលរដ្ឋ | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | - ការងាររដ្ឋបាលនិងច្បាប់<br>- កុំព្យូទ័រ | ធ្លាប់ធ្វើការងាររដ្ឋបាល |
| ៧ | មន្ត្រីជួរក្រោយផ្នែកពាណិជ្ជកម្ម | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | - ចុះបញ្ជីពាណិជ្ជកម្ម<br>- ស្រង់ទិន្នន័យ<br>- ចងក្រងបញ្ជីសេវា | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬ ការិយាល័យពាណិជ្ជកម្មក្រុង ស្រុក ខណ្ឌ |
| ៨ | មន្ត្រីជួរក្រោយផ្នែកវប្បធម៌ និងវិចិត្រសិល្បៈ | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | វប្បធម៌ និងវិចិត្រសិល្បៈ | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬ ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈក្រុង ស្រុក ខណ្ឌ |
| ៩ | មន្ត្រីជួរក្រោយផ្នែកទេសចរណ៍ | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | - ផ្នែកទេសចរណ៍<br>- ផ្នែកស្ថិតិមូលដ្ឋានអាជីវកម្ម សេវាកម្ម | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬ ការិយាល័យទេសចរណ៍ ក្រុង ស្រុក ខណ្ឌ |
| ១០ | មន្ត្រីជួរក្រោយផ្នែកឧស្សាហកម្ម រ៉ែ និងថាមពល | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | ស្រាវជ្រាវ អង្កេតផ្នែកសុវិធាន និងអសុវិធាន | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬ ការិយាល័យឧស្សាហកម្ម រ៉ែ និងថាមពលក្រុង ស្រុក ខណ្ឌ |
| ១១ | មន្ត្រីជួរក្រោយផ្នែកសំណង់ | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | ស្ថាបត្យករចាប់ពីមធ្យមឡើង | ផ្នែកសំណង់ | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ក្រុង ស្រុក ខណ្ឌ |

| | | | | | |
|---|---|---|---|---|---|
| ១២ | មន្ត្រីជួរក្រោយផ្នែកសាធារណការ និងដឹកជញ្ជូន | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | ផ្នែកសាធារណការ និងដឹកជញ្ជូន | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬការិយាល័យសាធារណការ និងដឹកជញ្ជូន ក្រុង ស្រុក ខណ្ឌ |
| ១៣ | មន្ត្រីជួរក្រោយផ្នែកអប់រំ យុវជន និងកីឡា | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | ផ្នែករដ្ឋបាល ឬគ្រូមធ្យម | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ |
| ១៤ | មន្ត្រីជួរក្រោយផ្នែកសុខាភិបាល | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | - ផ្នែកវេជ្ជសាស្ត្រ<br>- ផ្នែកឱសថសាស្ត្រ<br>- ផ្នែកសុខភាពសាធារណៈ | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬ ការិយាល័យសុខាភិបាលក្រុងស្រុក ខណ្ឌ |
| ១៥ | មន្ត្រីជួរក្រោយផ្នែកកសិកម្ម | មិនកំណត់ក្របខ័ណ្ឌ និងឋានន្តរសក្តិ | មធ្យមសិក្សាកំរិត២ (សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ) ឡើងទៅ | ផ្នែកកសិកម្ម និងបសុសត្វ | ធ្លាប់ ឬកំពុងបំពេញការងារផ្តល់សេវារដ្ឋបាលនៅមន្ទីរ ឬ ការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៣

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង